**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០៥៤/២៦ ន. គ. ស/សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការទទួលស្គាល់គ្រឹះស្ថានបណ្ដុះបណ្ដាលក្រោមគម្រោង ស្ដីពីការលើកកម្ពស់អនុលោមភាពគណនេយ្យ

## អគ្គនាយកនិយ័តករគណនេយ្យនិងសវនកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ. បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃស្ថាប័នវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម

- បានឃើញសេចក្ដីណែនាំលេខ០០២ អ.ស.ហ.សណន ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦ ស្ដីពីការអនុវត្តគម្រោងស្ដីពីការលើកកម្ពស់អនុលោមភាពគណនេយ្យ
- យោងតាមតម្រូវការចាំបាច់របស់និយ័តករគណនេយ្យនិងសវនកម្ម

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

សេចក្ដីសម្រេចនេះកំណត់អំពីលក្ខណវិនិច្ឆ័យ បែបបទ និងនីតិវិធីសម្រាប់ការទទួលស្គាល់គ្រឹះស្ថានបណ្ដុះបណ្ដាល ក្រុមហ៊ុន និងវិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលមានបំណងទទួលបានសិទ្ធិបណ្ដុះបណ្ដាលក្រោមគម្រោងស្ដីពី**ការលើកកម្ពស់អនុលោមភាពគណនេយ្យ**។

**ប្រការ២ ._**

សេចក្ដីសម្រេចនេះមានវិសាលភាពអនុវត្តចំពោះគ្រឹះស្ថានបណ្ដុះបណ្ដាល ក្រុមហ៊ុន និងវិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលមានបំណងទទួលយកការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលក្រោមគម្រោង "ការលើកកម្ពស់អនុលោមភាពគណនេយ្យ" នៅព្រះរាជាណាចក្រកម្ពុជា។

គ្រឹះស្ថានបណ្ដុះបណ្ដាល ក្រុមហ៊ុន និងវិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលទទួលបានសិទ្ធិក្នុងការបណ្ដុះបណ្ដាលក្រោមគម្រោងនេះ ត្រូវបានហៅថា **គ្រឹះស្ថានដែលបានទទួលស្គាល់**។

## ជំពូកទី២

## លក្ខណវិនិច្ឆ័យសម្រាប់ការទទួលស្គាល់

**ប្រការ៣ ._**

ដើម្បីទទួលបានសិទ្ធិក្នុងការបណ្ដុះបណ្ដាលកម្មវិធីក្រោមគម្រោងស្ដីពី ការលើកកម្ពស់អនុលោមភាពគណនេយ្យ គ្រឹះស្ថានបណ្ដុះបណ្ដាល ក្រុមហ៊ុន និងវិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវមានលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- បានចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារស្របតាមច្បាប់និង/ឬលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា
- ធ្លាប់រៀបចំការបណ្ដុះបណ្ដាលលើជំនាញគណនេយ្យ ឬកម្មវិធីគណនេយ្យលើសពីរយៈពេល ១(មួយ)ឆ្នាំឡើងទៅ
- បានអនុវត្តកាតព្វកិច្ចដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុ និងកាតព្វកិច្ចពាក់ព័ន្ធត្រឹមត្រូវ
- មានគ្រូឧទ្ទេស ឬសាស្ត្រាចារ្យ ដែលមានគុណវុឌ្ឍិដូចខាងក្រោម៖
  - ជាសមាជិកសកម្ម ឬសមាជិកចូលរួមរបស់ វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (**វ.គ.ស.ក.**) ឬជាគណនេយ្យករជំនាញកម្ពុជា ឬ ក្នុងតំបន់ និងអន្តរជាតិដែលទទួលស្គាល់ដោយ **ន.គ.ស.** ឬ

- បាននឹងកំពុងសិក្សាកម្មវិធីសិក្សាគណនេយ្យករជំនាញរបស់សមាគមគណនេយ្យករជំនាញជាន់ខ្ពស់ (ACCA) ដោយបានប្រឡងជាប់មុខវិជ្ជាទាំងអស់ក្នុងកម្រិតមូលដ្ឋាន កម្រិតមធ្យម និងបានប្រឡងជាប់មុខវិជ្ជា Ethics and Professional Skills and Strategic Business Reporting ឬ
- បាននឹងកំពុងសិក្សាកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជាដោយបានប្រឡងជាប់មុខវិជ្ជាទាំងអស់ក្នុងកម្រិត១(មូលដ្ឋាន) កម្រិត២(មធ្យម) និងបានប្រឡងជាប់មុខវិជ្ជាការរាយការណ៍ និងការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុកម្រិតខ្ពស់ និង
- បានប្រឡងជាប់កម្មវិធីសិក្សាគ្រូបង្គោលក្រោមគម្រោងការលើកកម្ពស់អនុលោមភាពគណនេយ្យ
- មានបទពិសោធបង្រៀនយ៉ាងតិច២(ពីរ)ឆ្នាំ និង

- លក្ខណវិនិច្ឆ័យផ្សេងទៀតតាមការតម្រូវដែលកំណត់ដោយ **ន.គ.ស.**។

## ជំពូកទី៣
## បែបបទ និងនីតិវិធីនៃការដាក់ពាក្យស្នើសុំដើម្បីទទួលបានការទទួលស្គាល់

**ប្រការ៤.-**

គ្រឹះស្ថានបណ្តុះបណ្តាល ក្រុមហ៊ុន និងវិទ្យាស្ថានបណ្តុះបណ្តាល ដែលមានលក្ខណវិនិច្ឆ័យដូចមានកំណត់ក្នុងប្រការ៣ នៃសេចក្តីសម្រេចនេះអាចដាក់ពាក្យស្នើសុំមក **ន.គ.ស.** តាមរយៈប្រព័ន្ធអនឡាញដែលមាននៅលើគេហទំព័ររបស់ **ន.គ.ស.** www.acar.gov.kh ដោយភ្ជាប់មកជាមួយនូវឯកសារភ្ជាប់ដូចមានចែងក្នុងប្រការ៥ នៃសេចក្តីសម្រេចនេះ។

**ប្រការ៥.-**

ឯកសារភ្ជាប់អំឡុងដាក់ពាក្យស្នើសុំដើម្បីទទួលបានការទទួលស្គាល់ជាគ្រឹះស្ថានបណ្តុះបណ្តាលក្រោមគម្រោងស្តីពីការលើកកម្ពស់អនុលោមភាពគណនេយ្យជាឯកសារថតចម្លង មានដូចខាងក្រោម៖

- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈរបស់ក្រុមហ៊ុន
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ពន្ធប៉ាតង់
- វិញ្ញាបនបត្របញ្ជាក់ថាបានទទួលការបណ្តុះបណ្តាលជំនាញគណនេយ្យឬកម្មវិធីគណនេយ្យ
- បង្កាន់ដៃបង់ប្រាក់ដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុរបស់ **ន.គ.ស.**
- ចំពោះសាស្ត្រាចារ្យ ឬគ្រូឧទ្ទេសត្រូវមាន៖
  - វិញ្ញាបនបត្របញ្ជាក់សមាជិកភាពរបស់ **វ.គ.ស.ក.** (មានបញ្ជាក់ត្រឹមត្រូវ) ឬវិញ្ញាបនបត្របញ្ជាក់ជាគណនេយ្យករជំនាញកម្ពុជា ឬក្នុងតំបន់ ឬអន្តរជាតិ ឬវិញ្ញាបនបត្របញ្ជាក់ការប្រឡងជាប់មុខវិជ្ជាតម្រូវក្រោមកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ឬ
  - វិញ្ញាបនបត្របញ្ជាក់ថាបានប្រលងជាប់មុខវិជ្ជាទាំងអស់ក្នុងកម្រិតមូលដ្ឋាន កម្រិតមធ្យម និងបានប្រឡងជាប់មុខវិជ្ជា Ethics and Professional Skills and Strategic Business Reporting នៃកម្មវិធីសិក្សាគណនេយ្យករជំនាញរបស់សមាគមគណនេយ្យករជំនាញជាន់ខ្ពស់

(ACCA) ឬ វិញ្ញាបនបត្របញ្ជាក់ថាបានប្រលងជាប់មុខវិជ្ជាទាំងអស់ក្នុងកម្រិត១(មូលដ្ឋាន) កម្រិត២(មធ្យម) និងបានប្រឡងជាប់មុខវិជ្ជាការរាយការណ៍និងការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុកម្រិតខ្ពស់នៃកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា

- វិញ្ញាបនបត្រវគ្គបណ្តុះបណ្តាលគ្រូបង្គោលក្រោមគម្រោងស្តីពីការលើកកម្ពស់អនុលោមភាពគណនេយ្យ
- លិខិតបញ្ជាក់បទពិសោធបង្រៀនមុខវិជ្ជាគណនេយ្យ និងមុខវិជ្ជាពាក់ព័ន្ធនឹងគម្រោង

- ឯកសារពាក់ព័ន្ធផ្សេងទៀតតាមការតម្រូវរបស់ **ន.គ.ស.** តាមការចាំបាច់។

**ប្រការ៦ .-**

**ន.គ.ស.** ឆ្លើយតបចំពោះការស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ ដោយគិតចាប់ពីថ្ងៃដាក់ពាក្យស្នើសុំ និងមានឯកសារភ្ជាប់ពេញលេញ។

**ប្រការ៧ .-**

គ្រឹះស្ថានបណ្តុះបណ្តាល ក្រុមហ៊ុន និងវិទ្យាស្ថានបណ្តុះបណ្តាល ត្រូវបង់កម្រៃនៃការដាក់ពាក្យ និងសិក្សាសំណុំឯកសារចំនួន ៨០០,០០០ (ប្រាំបីសែន) រៀល នៅពេលដាក់ពាក្យស្នើសុំតាមរយៈគណនីធនាគាររបស់ **ន.គ.ស.**។

កម្រៃនៃការដាក់ពាក្យស្នើសុំ និងសិក្សាសំណុំឯកសារដែលបានបង់មក **ន.គ.ស.** មិនអាចដកវិញបានឡើយ។

**ប្រការ៨ .-**

គ្រឹះស្ថានបណ្តុះបណ្តាល ក្រុមហ៊ុន និងវិទ្យាស្ថានបណ្តុះបណ្តាល ដែលបានបំពេញលក្ខណវិច្ឆ័យដូចមានកំណត់ក្នុងប្រការ៣ នៃសេចក្តីសម្រេចនេះ ត្រូវចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយ **ន.គ.ស.** ដើម្បីទទួលបានការទទួលស្គាល់ជាគ្រឹះស្ថានបណ្តុះបណ្តាល។

សុពលភាពនៃការទទួលបានសិទ្ធិក្នុងការបណ្តុះបណ្តាលក្រោមគម្រោងខាងលើពី **ន.គ.ស.** មានរយៈពេល៣(បី)ឆ្នាំ។

គ្រឹះស្ថានសិក្សាដែលទទួលបានការទទួលស្គាល់ ដែលមានបំណងបន្តសិទ្ធិក្នុងការបណ្តុះបណ្តាលក្រោមគម្រោងខាងលើ ត្រូវដាក់ពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយ **ន.គ.ស.** យ៉ាងតិច៤៥(សែសិបប្រាំ) ថ្ងៃ មុនថ្ងៃផុតកំណត់សុពលភាព។

**ប្រការ៩ .-**

គ្រឹះស្ថានដែលបានទទួលស្គាល់ ត្រូវបាត់បង់សិទ្ធិបណ្តុះបណ្តាលពី **ន.គ.ស.** ក្នុងករណីណាមួយដូចខាងក្រោម៖

- សិទ្ធិបណ្តុះបណ្តាលក្រោមគម្រោងនេះអស់សុពលភាព
- បាត់បង់លក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រការ៣ នៃសេចក្តីសម្រេចនេះ
- មិនអនុវត្តកាតព្វកិច្ចណាមួយដូចមានចែងក្នុងប្រការ១០ នៃសេចក្តីសម្រេចនេះ
- មិនអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៣
## ភារកិច្ចរបស់គ្រឹះស្ថានដែលបានទទួលស្គាល់

**ប្រការ១០ ._**

គ្រឹះស្ថានដែលបានទទួលស្គាល់មានភារកិច្ចដូចខាងក្រោម៖

- ប្រើប្រាស់ឧបករណ៍ និងឯកសារបណ្តុះបណ្តាលផ្លូវការទាំងអស់ដែលបានអភិវឌ្ឍដោយ **ន.គ.ស.**
- ចូលរួមក្នុងកិច្ចដំណើរការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងឧបករណ៍សិក្សាដែលរៀបចំដោយ **ន.គ.ស.**
- តម្រូវឱ្យសាស្ត្រាចារ្យបង្រៀនកម្មវិធីសិក្សានេះចូលរួមការបណ្តុះបណ្តាលបន្ត ដែលរៀបចំដោយ **ន.គ.ស.**
- អនុវត្តតាមកម្រៃសិក្សានិងកម្រៃសេវាពាក់ព័ន្ធដែលកំណត់ដោយ **ន.គ.ស.**
- រក្សាចំនួនសិស្ស ឬនិសិត្សដែលបានចុះឈ្មោះប្រឡងអប្បបរមាជាមួយកម្មវិធីចំនួន ១៥ នាក់ក្នុងមួយឆ្នាំ
- គោរពវិធាន និងគោលការណ៍ណែនាំពាក់ព័ន្ធដែលកំណត់ដោយ **ន.គ.ស.**។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១១ ._**

គ្រឹះស្ថានដែលបានទទួលស្គាល់ និងគ្រប់បុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២៦

**អគ្គនាយក**

**ប៊ូ ថារិន**

**កន្លែងទទួល៖**

- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា **អ.ស.ហ.**
  "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ១១
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ